**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

PHNOM PENH AUTONOMOUS PORT

**កំពង់ផែស្វយ័តភ្នំពេញ**

លេខ: ០៥៩០.......ក.ស.ភ.

ថ្ងៃអង្គារ ១០កើតខែអស្សុជ ឆ្នាំវក ព.ស២៥៦០

រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែតុលា គ.ស.២០១៦

## សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

## ការចុះហត្ថលេខា រវាងកំពង់ផែស្វយ័តភ្នំពេញ និងក្រុមហ៊ុន វៀត សាក់ ផត សឺវីស (ខេមបូឌា) ខូអិលធីឌី លើកិច្ចសន្យាស្តីពីកិច្ចសហប្រតិបត្តិការផ្តល់សេវាកម្មថែទាំ និងជួសជុលសំបកកុងតឺន័រ

នាព្រឹកថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៦ នៅទីស្នាក់ការកណ្តាលនៃកំពង់ផែស្វយ័តភ្នំពេញ (ក.ស.ភ.) ជិតគល់ស្ពានជ្រោយចង្វារ ក.ស.ភ. បានចុះហត្ថលេខាជាមួយក្រុមហ៊ុន **វៀត សាក់ ផត សឺវីស (ខេមបូឌា) ខូអិលធីឌី (Viet Sac Port Services (Cambodia) Co., Ltd.)** លើកិច្ចសន្យាស្តីពីកិច្ចសហប្រតិបត្តិការផ្តល់សេវាកម្មថែទាំ និងជួសជុលសំបកកុងតឺន័រ (Container Maintenance and Repair Service) ។ ការផ្តល់សេវាកម្មថែទាំ និងជួសជុលសំបកកុងតឺន័រនេះ ត្រូវបានធ្វើឡើងក្នុងបរិវេណនៃចំណតផែកុងតឺន័រ LM១៧ របស់ ក.ស.ភ. ដែលមានទីតាំងស្ថិតនៅក្នុងភូមិកណ្តាលលើ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល។ សេវាកម្មថែទាំ និងជួសជុលសំបកកុងតឺន័រនេះ ជាប្រភេទសេវាកម្មថ្មីមួយទៀត បន្ថែមលើសេវាកម្មនានារបស់ ក.ស.ភ. ដែលមានសព្វថ្ងៃ។

ក្រុមហ៊ុន វៀត សាក់ ផត សឺវីស (ខេមបូឌា) ខូអិលធីឌី គឺជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុន Newport Overland Transportation Joint Stock Company ដែលមានជំនាញ និងបទពិសោធន៍ជាច្រើនឆ្នាំលើការថែទាំ និងជួសជុល សំបកកុងតឺន័រនៅក្នុងសាធារណរដ្ឋសង្គមនិយមវៀតណាម។

សេវាកម្មថែទាំ និងជួសជុលសំបកកុងតឺន័រនេះ នឹងចាប់ផ្តើមដំណើរការចាប់ពីខែតុលា ឆ្នាំ២០១៦ នេះតទៅ។

**កំពង់ផែស្វយ័តភ្នំពេញ**

PHNOM PENH AUTONOMOUS PORT
កំពង់ផែស្វយ័តភ្នំពេញ

ទីស្នាក់ការកណ្តាល: អគារលេខ ៦៤៩ តិរវិថីព្រះស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ/ទូរសារ (៨៥៥) ៤២៧ ៨០២ Email: ppapmpwt@online.com.kh / info@ppap.com.kh